# បច្ចេកវិទ្យាសម្រាប់សហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា

បច្ចុប្បន្ន សហគ្រាសធុនតូច និងមធ្យម (SMEs) បានដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ជាពិសេសសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ ដោយបានរួមចំណែកប្រមាណ ៤០% នៃផលិតផលក្នុងស្រុកសរុប (GDP) នៅកម្រិតសកល នេះបើយោងតាមធនាគារពិភពលោក (World Bank)។ អាជីវកម្មប្រហែល ៩០% ជាសហគ្រាសធុនតូច និងមធ្យម ហើយអាជីវកម្មទាំងនេះបានចូលរួមចំណែកក្នុងការបង្កើតឱកាសការងារដល់ប្រជាពលរដ្ឋលើសពី ៥០% នៅជុំវិញពិភពលោក។ ជាងនេះទៅទៀត តម្រូវការការងារនឹងមានចំនួនប្រមាណ ៦០០លាន នៅត្រឹមឆ្នាំ២០៣០ ខាងមុខនេះ ស្របតាមកំណើនកម្លាំងពលកម្មពិភពលោក ដែលធ្វើឱ្យការអភិវឌ្ឍវិស័យសហគ្រាសធុនតូច និងមធ្យម បានក្លាយជាអាទិភាពចម្បងមួយសម្រាប់រដ្ឋាភិបាលនៃបណ្តាប្រទេសនានានៅជុំវិញពិភពលោក។ យោងតាមតួលេខចុងក្រោយ ការងារផ្លូវការចំនួន ៧ ក្នុងចំណោម ១០ ត្រូវបានបង្កើតឡើងដោយសហគ្រាសធុនតូច និងមធ្យម នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។

សហគ្រាសធុនតូច និងមធ្យមត្រូវបានគេឱ្យនិយមន័យផ្សេងៗគ្នាទៅតាមបរិបទប្រទេសនីមួយៗ។ ជាទូទៅ ការកំណត់និយមន័យរបស់សហគ្រាសធុនតូច និងមធ្យម គឺធ្វើឡើងដោយផ្អែកលើចំនួននិយោជិត (និយោជិតដែលធ្វើការពេញម៉ោង) និងផលរបរប្រចាំឆ្នាំ ឬទំហំទ្រព្យសកម្មរបស់ស្ថាប័ន។ សម្រាប់កម្ពុជា យោងតាមលិខិតរបស់**ទីស្តីការគណៈរដ្ឋមន្ត្រី** លេខ៣៦សជណ.ហធ ស្តីពី ករណីលទ្ធផល**កិច្ចប្រជុំគណៈកម្មាធិការគោលនយោបាយលើកស្ទួយសហគ្រាសធុនតូច និងមធ្យម លើកទី២** រាជរដ្ឋាភិបាលបានសម្រេចកំណត់និយមន័យ «**សហគ្រាសធុនតូច និងមធ្យម**» ដោយបែងចែកជា ៣ វិស័យ រួមមាន វិស័យកសិកម្ម វិស័យឧស្សាហកម្ម វិស័យសេវាកម្ម និងពាណិជ្ជកម្ម។ វិស័យនីមួយៗ ត្រូវភ្ជាប់នូវលក្ខខណ្ឌតម្រូវ ២ គឺ៖ ១). ចំនួនបុគ្គលិក  និង២).ទំហំផលរបរប្រចាំឆ្នាំ ឬ ទំហំទ្រព្យសកម្ម។

សម្រាប់លក្ខខណ្ឌទី២ ក្រសួង ស្ថាប័នពាក់ព័ន្ធអាចប្រើប្រាស់លក្ខខណ្ឌណាមួយក៏បាន ប៉ុន្តែករណីផលរបរប្រចាំឆ្នាំ និងទ្រព្យសកម្មមិនមានសង្គតិភាពក្នុងការកំណត់សហគ្រាសជា SMEs ត្រូវយកលក្ខខណ្ឌដែលមានកម្រិតខ្ពស់ជាងគេ។

ការកំណត់និយមន័យ ត្រូវបែងចែកលម្អិតទៅតាមវិស័យសំខាន់ៗដូចខាងក្រោម៖

**សម្រាប់វិស័យកសិកម្ម** សហគ្រាសធុនតូចត្រូវបានកំណត់សម្រាប់ស្ថាប័នដែលមានបុគ្គលិកចន្លោះពី ៥ ទៅ ៤៩ នាក់ ជាមួយនិងផលរបរប្រចាំឆ្នាំចាប់ពី ៦២ ២៥០ ដុល្លារទៅ ២៥០ ០០០ ដុល្លារ។

ទំហំទ្រព្យសកម្មសម្រាប់សហគ្រាសធុនតូចត្រូវបានកំណត់ពី៥០ ០០០ ទៅ ២៥០ ០០០ ដុល្លារ។ សហគ្រាសធុនមធ្យមត្រូវបានកំណត់ថាជាស្ថាប័នដែលមានបុគ្គលិកចន្លោះពី ៥០ ទៅ ១៩៩នាក់ ដែលមានផលរបរប្រចាំឆ្នាំពី ២៥០ ០០១ ទៅ ១ ០០០ ០០០ ដុល្លារ។ ទំហំទ្រព្យសម្បត្តិសម្រាប់សហគ្រាសធុនមធ្យមត្រូវបានកំណត់ពី ២៥០ ០០១ ទៅ ៥០០ ០០០ ដុល្លារ។

***សម្រាប់វិស័យឧស្សាហកម្ម*** សហគ្រាសធុនតូចត្រូវបានកំណត់ជាស្ថាប័នដែលមានបុគ្គលិកចន្លោះពី ៥ ទៅ ៤៩ នាក់ និងមានផលរបរប្រចាំឆ្នាំចាប់ពី ៦២ ៥០០ ទៅ ៤០០ ០០០ ដុល្លារ។ ទំហំទ្រព្យសកម្មសម្រាប់សហគ្រាសខ្នាតតូចត្រូវបានកំណត់ពី ៥០ ០០០ ទៅ ៥០០ ០០០ ដុល្លារ។ សហគ្រាសធុនមធ្យមត្រូវបានកំណត់សម្រាប់ស្ថាប័នដែលមានបុគ្គលិកចន្លោះពី ៥០ ទៅ ១៩៩នាក់ដែលមានផលរបរប្រចាំឆ្នាំពី ៤០ ០០០១ ទៅ ២ ០០០ ០០០ ដុល្លារ។ ទំហំទ្រព្យសកម្មសម្រាប់សហគ្រាសមធ្យមត្រូវបានកំណត់ពី ៥០០ ០០១ ទៅ ១ ០០០ ០០០ ដុល្លារ។

***សម្រាប់វិស័យសេវាកម្ម និងពាណិជ្ជកម្ម*** សហគ្រាសធុនតូចត្រូវបានកំណត់សម្រាប់ស្ថាប័នដែលមានបុគ្គលិកចន្លោះពី ៥ ទៅ ៤៩ នាក់ ដែលមានផលរបរប្រចាំឆ្នាំចាប់ពី ៦២ ៥០០ ទៅ ២៥០ ០០០ ដុល្លារ។ ទំហំទ្រព្យសកម្មសម្រាប់សហគ្រាសខ្នាតតូចត្រូវបានកំណត់ពី ៥០ ០០០ ទៅ២៥០ ០០០ ដុល្លារ។ ខណៈដែលសហគ្រាសធុនមធ្យមត្រូវបានកំណត់សម្រាប់ស្ថាប័នដែលមានបុគ្គលិកចន្លោះពី ៥០ ទៅ ៩៩ នាក់ ដែលមានផលរបរប្រចាំឆ្នាំពី ២៥០ ០០១ ទៅ ១ ៥០០ ០០០ ដុល្លារ។ ទំហំទ្រព្យសម្បត្តិសម្រាប់សហគ្រាសមធ្យមត្រូវបានកំណត់ពី ២៥០ ០០១ ទៅ ៥០០ ០០០ ដុល្លារ។

នៅប្រទេសកម្ពុជា សហគ្រាសធុនតូច និងមធ្យម តំណាងឱ្យប្រមាណជាង ៩០% នៃអាជីវកម្មសរុប និងរួមចំណែកប្រមាណ ៦០% នៃផលិតផលក្នុងស្រុកសរុប។ ក្នុងន័យនេះ សហគ្រាសធុនតូច និងមធ្យមបានដើរតួយ៉ាងសំខាន់ក្នុងការអភិវឌ្ឍប្រទេសកម្ពុជា តាមរយៈការបង្កើតឱកាសការងារ ប្រមាណ ៧០% នៃការងារសរុប, ការបង្កើនប្រាក់ចំណូលសម្រាប់ប្រជាជនដែលមានចំណូលទាប និងប្រជាជនងាយរងគ្រោះ, ការរួមចំណែកដល់ការរីកចម្រើននៃវិស័យឯកជន ព្រមទាំងការជំរុញកំណើនសេដ្ឋកិច្ច និងស្ថេរភាពសង្គម។

## I. បច្ចេកវិទ្យាដែលមានសក្តានុពលសម្រាប់សហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា

### ➤ ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក៖

ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅកម្ពុជាកំពុងមានសន្ទុះកំណើនខ្លាំងក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដោយសារការកើនឡើងនៃចំនួនអ្នកប្រើប្រាស់ទូរស័ព្ទដៃឆ្លាតវៃ, បណ្តាញ 3G ដែលអាចប្រើប្រាស់បានយ៉ាងទូលំទូលាយ និងការកើនឡើងនៃចំនួនអ្នកប្រើប្រាស់ដែលចូលចិត្តស្វែងរក និងទិញផលិតផលតាមប្រព័ន្ធអ៊ីនធឺណិត ជាពិសេសនៅអំឡុងពេលនៃការឆ្លងរាលដាលជំងឺកូវីដ-១៩។ ដូច្នេះ សហគ្រាសធុនតូច និងមធ្យមនៅកម្ពុជាអាចចាប់យកកាលានុវត្តភាពពីការធ្វើពាណិជ្ជកម្មតាម

ប្រព័ន្ធអេឡិចត្រូនិក ដើម្បីអាចជ្រៀតចូលទាំងទីផ្សារក្នុងស្រុក និងទីផ្សារអន្តរជាតិ។




### ➤ ការធ្វើទីផ្សារតាមបែបឌីជីថល (Digital Marketing)៖

សហគ្រាសធុនតូច និងមធ្យម និងអាជីវកម្មលក្ខណៈគ្រួសារ អាចចាប់យកសក្តានុពល និងទាញយកផលប្រយោជន៍ពីការធ្វើទីផ្សារតាមបែបឌីជីថល ពិសេសការប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គម ដូចជា Facebook, Instagram, និងYouTube ជាដើម ដោយអាចផ្សព្វផ្សាយ តាមទំហំនៃតម្រូវការ និងលទ្ធភាពហិរញ្ញវត្ថុរបស់ខ្លួន ទាំងការផ្សព្វផ្សាយនៅលើ Page ផ្ទាល់ខ្លួន និងការប្រើប្រព័ន្ធផ្សព្វផ្សាយដែលបង់ប្រាក់ ដូចជា ការផ្សព្វផ្សាយផលិតផល និងសេវានៅតាមគេហទំព័រនានា, ការបង្កើនប្រសិទ្ធភាពម៉ាស៊ីនស្វែងរក (Search Engine Optimization-SEO) និងការឃោសនាផលិតផលតាមរយៈអ៊ីម៉ែល ដែលសុទ្ធតែអាចជួយឱ្យម្ចាស់អាជីវកម្មបង្កើនការលក់ផលិតផល ឬសេវាកម្មបាន។



## បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍៖

សហគ្រាសធុនតូច និងមធ្យមនៅកម្ពុជាក៏អាចទាញយកផលប្រយោជន៍ពីការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ (ICT) សំរាប់អាជីវកម្មរបស់ពួកគេតាមរយៈការប្រើប្រាស់កម្មវិធីប្រជុំតាមប្រព័ន្ធអ៊ីនធឺណិតមួយចំនួនដូចជា GoToMeeting, Zoom និង Skype។ កម្មវិធីទាំងនេះ អាចជួយអាជីវកម្មក្នុងការកាត់បន្ថយពេលវេលា និងចំណេញថវិកា ក៏ដូចជាការរក្សានៅទំនាក់ទំនងជាមួយអតិថិជន។ លើសពីនេះទៀត ICT បានអនុញ្ញាតឱ្យសហគ្រាសអាចបន្តអាជីវកម្ម ទោះបីជានៅក្នុងកាលៈទេសៈនៃវិបត្តិជំងឺកូវីត-១៩ក៏ដោយ ក្នុងនោះបុគ្គលិកអាចបំពេញការងាររបស់ខ្លួនដោយពុំចាំបាច់មានវត្តមាននៅក្នុងការិយាល័យ ក៏ដូចជាការទទួលបានព័ត៌មាន និងរក្សាទំនាក់ទំនងជាមួយមិត្តរួមការងារ។



## ការធ្វើគេហទំព័រសម្រាប់អាជីវកម្ម៖

នៅក្នុងយុគសម័យឌីជីថល សហគ្រាសធុនតូច និងមធ្យមត្រូវការគេហទំព័រផ្ទាល់ខ្លួន ដើម្បីងាយស្រួលភ្ជាប់ទំនាក់ទំនងជាមួយអតិថិជន និងធ្វើការផ្សព្វផ្សាយពីផលិតផល ឬសេវាកម្មនានា។ ឥឡូវនេះ សហគ្រិនអាចបង្កើតគេហទំព័រអាជីវកម្មដោយខ្លួនឯងផ្ទាល់បានយ៉ាងងាយស្រួល ដោយមិនចាំបាច់ជួលអ្នកជំនាញក៏បាន ដោយអាចសាកល្បងប្រើប្រាស់ថ្នាលឌីជីថលមួយចំនួន ដូចជា Zyro, Shopify, Weebly, About.me, Wordpress.com, Jimdo, WordPress.com, Webnote, Wix, Volusion និងBigcommerce។



## ការទូទាត់ដោយមិនប្រើក្រដាសប្រាក់ (Cashless Payment)៖

ការទូទាត់ដោយគ្មានសាច់ប្រាក់បានទទួលការគាំទ្រច្រើនជាងមុន ហើយក៏ត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយដោយសហគ្រាសធុនតូច និងមធ្យម និងអាជីវកម្មលក្ខណៈគ្រួសារ សម្រាប់ផ្តល់ភាពងាយស្រួលដល់ការទូទាត់ប្រាក់របស់អតិថិជន។ សេវាទូទាត់តាមឌីជីថល និងចល័តដែលកំពុងប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជាមានដូចជា កម្មវិធីទូរស័ព្ទ ABA, True Money, Pi Pay, SmartLuy, PayGo, Wing, DaraPay, AEON Wallet Cambodia និងGrabPay។ ក្រៅពីកម្មវិធីទូរស័ព្ទទាំងនេះ ធនាគារនៅប្រទេសកម្ពុជាក៏មានផ្តល់ជាសេវាកម្មធនាគារចល័ត (Mobile Banking) ដែលបានសម្រួលដល់ការទូទាត់កាន់តែមានភាពងាយស្រួល រហ័ស និងសុវត្ថិភាព។ លើសពីនេះទៀត ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការ "កម្មវិធីបាគង" ដែលប្រព័ន្ធថ្មីនេះបានជួយឱ្យអ្នកប្រើប្រាស់សេវាធនាគារតាមរយៈប្រព័ន្ធទូរស័ព្ទ មានភាពងាយស្រួលក្នុងការទូទាត់ប្រាក់ឆ្លងពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុមួយទៅគ្រឹះស្ថានមួយទៀត ព្រមទាំងពង្រឹងសុវត្ថិភាពប្រព័ន្ធទូទាត់ ជំរុញបរិយាបន្នហិរញ្ញវត្ថុ និងជំរុញការទូទាត់ដោយមិនប្រើក្រដាសប្រាក់នៅកម្ពុជា។



## ប្រព័ន្ធកុំព្យូទ័រភ្លោដ (Cloud Computing)៖

អំឡុងពេលនៃការរីករាលដាលនៃជំងឺកូវីដ-១៩ ការប្រើប្រាស់ប្រព័ន្ធកុំព្យូទ័រភ្លោដ អាចជួយឱ្យសហគ្រាសធុនតូច និងមធ្យមធ្វើការពីចម្ងាយ។ ប្រព័ន្ធកុំព្យូទ័រភ្លោដផ្ទុកទិន្នន័យនៅលើអ៊ីនធឺណិតជាជាងផ្ទុកក្នុងកំព្យូទ័រ ឬម៉ាស៊ីនមេ (Server)។ ដូច្នេះ និយោជិតអាចចូលប្រើប្រាស់ទិន្នន័យបានគ្រប់ពេលវេលា

និងគ្រប់ទីកន្លែងដែលមានអ៊ីនធឺណិត។ មិនតែប៉ុណ្ណោះ ការបាត់បង់ទិន្នន័យដែលអាចបណ្តាលមកពីការខូចខាតផ្នែករឹង (Hardware Failure) នឹងធ្វើឱ្យក្រុមហ៊ុនរងការខូចខាត អាជីវកម្មជួបបញ្ហាប្រឈម។ ក្នុងន័យនេះ ការផ្ទុកទិន្នន័យនៅលើប្រព័ន្ធកុំព្យូទ័រក្លោដ អាចជួយឱ្យម្ចាស់សហគ្រាសធុនតូច និងមធ្យម មិនបាច់បារម្ភពីការបាត់បង់ឯកសារសំខាន់ៗ ដោយសារការខូចខាតឧបករណ៍នានា។



**ទិន្នន័យធំ (Big Data)៖**

ជាទូទៅ គេយល់ឃើញថាមានតែក្រុមហ៊ុនធំៗ ដូចជា Google និង Facebook ដែលអាចទាញយកផលប្រយោជន៍ពីទិន្នន័យធំ។ ប៉ុន្តែបច្ចុប្បន្ននេះ សហគ្រាសធុនតូច និងមធ្យមក៏អាចទាញយកផលប្រយោជន៍ពីទិន្នន័យធំដូចគ្នា ដោយសារតែការកើនឡើងនូវដំណោះស្រាយទិន្នន័យធំមួយចំនួន ដូចជា SAS, Alteryx, Kissmetrics, InsightSquared, Google Analytics, IBM Cognos Analytics, Tranzlogic និង Qualtrics ដែលអនុញ្ញាតឱ្យសហគ្រាសធុនតូច និងមធ្យមធ្វើការវិភាគទិន្នន័យ ដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់ពីតម្រូវការរបស់អតិថិជន។




## › សន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត (Cybersecurity)៖

នៅសតវត្សរ៍ទី២១នេះ ការគំរាមកំហែងតាមប្រព័ន្ធអ៊ីនធឺណិត និងការរំលោភបំពានទិន្នន័យបានកើនឡើងជាលំដាប់។ យោងតាមគេហទំព័រ Techradar សហគ្រិនធុនតូច និងមធ្យម ជាង១លានត្រូវបានរងផលប៉ះពាល់ដោយការវាយប្រហារតាមប្រព័ន្ធអ៊ីនធឺណេតនៅឆ្នាំ២០១៨។ រាល់ការវាយប្រហារទាំងនេះត្រូវចំណាយជាមធ្យមជិត ៦ ៥០០ ដុល្លារ ដើម្បីដោះស្រាយ។ ហេតុដូចនេះ សហគ្រិនធុនតូច និងមធ្យមអាចចាប់ផ្ដើមប្រើប្រាស់បច្ចេកវិទ្យាដើម្បីការពារ ប្រឆាំងទប់ទល់នឹងការគំរាមកំហែងពីការវាយប្រហារតាមអ៊ីនធឺណិតនេះ។ ការពង្រឹងសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត មានចាប់ពីការប្រើប្រាស់ Software ដែលមានតម្លៃសមរម្យ រហូតដល់ការការពារពីអ្នកជំនាញផ្នែកសន្តិសុខអ៊ីនធឺណិត។



**➤ ស្វ័យប្រវត្តិកម្ម (Automation)៖**

ជាធម្មតា ស្វ័យប្រវត្តិកម្មត្រូវបានគេចាត់ទុកថាជាបច្ចេកវិទ្យាដែលប្រើប្រាស់ដោយក្រុមហ៊ុនធំៗ។ ប៉ុន្តែ ស្វ័យប្រវត្តិកម្មក៏អាចប្រើប្រាស់ដោយសហគ្រាសធុនតូច និងមធ្យម ដើម្បីបង្កើនផលិតភាព។ ស្វ័យប្រវត្តិកម្មការងារប្រចាំថ្ងៃមានដូចជា អ៊ីម៉ែល។ អ៊ីម៉ែលដែលប្រើស្វ័យប្រវត្តិកម្មអាចជាការផ្ញើអ៊ីម៉ែលស្វាគមន៍ដោយស្វ័យប្រវត្តិនៅពេលអតិថិជនចុះឈ្មោះចូលក្នុងវេបសាយ ឬកម្មវិធីណាមួយ ការផ្ញើអ៊ីម៉ែលណែនាំពីផលិតផលស្រដៀងគ្នាដោយស្វ័យប្រវត្តិ បន្ទាប់ពីអតិថិជនទិញទំនិញណាមួយរួច និងការផ្ញើអ៊ីម៉ែលរំលឹកអតិថិជនដោយស្វ័យប្រវត្តិនៅពេលជ្រើសរើសទំនិញណាមួយរួច តែមិនទាន់ធ្វើការទូទាត់ប្រាក់។




## II. អត្ថប្រយោជន៍នៃបច្ចេកវិទ្យាសម្រាប់សហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា

ខាងក្រោមនេះជាអត្ថប្រយោជន៍សំខាន់ៗមួយចំនួនដែលបច្ចេកវិទ្យាអាចផ្តល់ឱ្យសហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា៖

**➤ ពង្រឹងស័ក្តិសិទ្ធិភាពការងារ៖** បច្ចុប្បន្ននេះ បច្ចេកវិទ្យាថ្មីបានធ្វើឱ្យអាជីវកម្មមានភាពងាយស្រួលក្នុងការតាមដានការចំណាយ និងចំណូលបានលឿន និងត្រឹមត្រូវ។ មិនតែប៉ុណ្ណោះ បច្ចេកវិទ្យាក៏បានជួយឱ្យសហគ្រាសចំណេញពេលវេលា និងធនធាន ដោយហេតុថាឥឡូវនេះ បុគ្គលិកក្រុមហ៊ុនអាចជួបអតិថិជន និងវិនិយោគិនបានតាមប្រព័ន្ធអ៊ីនធឺណិតជាជាងការជួបជុំផ្ទាល់។ ម៉្យាងទៀត បច្ចេកវិទ្យាក៏បានជួយឱ្យបុគ្គលិកអាចធ្វើការពីចម្ងាយបានដែលជួយឱ្យសហគ្រាស សន្សំសំចៃលើការចំណាយនានា ដូចជា ការជួលការិយាល័យ និងការធ្វើដំណើរ ហើយម្ចាស់អាជីវកម្មក៏អាចតាមដានដំណើរការការងាររបស់បុគ្គលិកតាមប្រព័ន្ធអ៊ីនធឺណិត។

**បង្កើនផលិតភាព៖** បច្ចេកវិទ្យាបានជួយបង្កើនផលិតភាពការងារដល់សហគ្រាសធុនតូច និងមធ្យម ដោយជួយឱ្យការទំនាក់ទំនងរវាងបុគ្គលិកកាន់តែមានភាពងាយស្រួល និងមានប្រសិទ្ធភាព។ សហគ្រាសធុនតូច និងមធ្យម ក៏អាចប្រើប្រាស់ឧបករណ៍ និងកម្មវិធីបច្ចេកវិទ្យានានាដែលជួយសម្រួលដល់ដំណើរការការងារដែលស្មុគស្មាញ និងសន្សំសំចៃពេលវេលា។ មិនតែប៉ុណ្ណោះ ស្វ័យប្រវត្តិកម្មក៏បានជួយបង្កើនផលិតភាពការងារ និងកាត់បន្ថយកំហុសដែលប្រព្រឹត្តដោយមនុស្ស ដោយអនុញ្ញាតឱ្យបុគ្គលិកយកពេលវេលាទៅធ្វើការងារស្នូល និងសកម្មភាពសំខាន់ៗផ្សេងទៀត។

**ជួយក្នុងការសម្រេចចិត្តដោយផ្អែកលើទិន្នន័យ៖** បច្ចេកវិទ្យាទំនើបដូចជា ទិន្នន័យធំ អាចឱ្យសហគ្រាសធុនតូច និងមធ្យមដឹងពីនិន្នាការអាជីវកម្ម ដែលអាចជួយឱ្យអាជីវកម្មដំណើរការកាន់តែប្រសើរ ដោយហេតុថា ម្ចាស់អាជីវកម្មអាចធ្វើការសម្រេចចិត្តបានល្អ និងទាន់ពេលវេលាជាងមុនលើយុទ្ធសាស្ត្ររបស់ក្រុមហ៊ុន និងវិធីការពារអាជីវកម្មក្នុងពេលអនាគត។ មិនតែប៉ុណ្ណោះ ជាមួយនឹងបច្ចេកវិទ្យានេះ សហគ្រាសធុនតូច និងមធ្យម ក៏អាចធ្វើការព្យាករណ៍តម្រូវការរបស់អតិថិជនដែលអាចឱ្យផលិតផល ឬសេវាកម្មរបស់ក្រុមហ៊ុនទទួលបានការគាំទ្រកាន់តែច្រើន ហើយសហគ្រាសក៏អាចប្រើប្រាស់បច្ចេកវិទ្យាទាំងនេះដើម្បីធ្វើការព្យាករណ៍ការចំណាយឱ្យចំគោលដៅ។

**ផ្សារភ្ជាប់ទំនាក់ទំនងជាមួយអតិថិជនប្រកបដោយប្រសិទ្ធភាព៖** ផ្នែកមួយនៃភាពលូតលាស់របស់សហគ្រាសធុនតូច និងមធ្យម គឺអាស្រ័យលើសមត្ថភាពក្នុងការទំនាក់ទំនងជាមួយអតិថិជនប្រកបដោយប្រសិទ្ធភាព។ ក្នុងន័យនេះ គេហទំព័រអនុញ្ញាតឱ្យអតិថិជនស្វែងរកព័ត៌មានរបស់ក្រុមហ៊ុនបានយ៉ាងឆាប់រហ័ស ហើយប្រព័ន្ធផ្សព្វផ្សាយសង្គមក៏បានជួយឱ្យការទំនាក់ទំនងរវាងបុគ្គលិក និងអតិថិជនកាន់តែងាយស្រួល។ ជាមួយនឹងបច្ចេកវិទ្យាទាំងនេះ សហគ្រាសធុនតូច និងមធ្យមអាចធ្វើទីផ្សារ និងលក់ផលិតផល ឬសេវាកម្មដល់ប្រជាពលរដ្ឋបានយ៉ាងរហ័ស និងងាយស្រួល។ មិនតែប៉ុណ្ណោះ ការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពជួយបង្កើនទំនុកចិត្តដល់អតិថិជនចំពោះក្រុមហ៊ុន។ ក្រុមហ៊ុនអាចទទួលបាននូវការវាយតម្លៃ និងមតិយោបល់ពីអតិថិជនទៅលើសេវាកម្ម ឬផលិតផលរបស់ពួកគេតាមរយៈគេហទំព័រ ឬប្រព័ន្ធផ្សព្វផ្សាយសង្គម។ ដូច្នេះ អាជីវកម្មអាចកែលម្អផលិតផល ឬសេវាកម្មរបស់ខ្លួនដើម្បីបង្កើនភាពប្រកួតប្រជែងនៅលើទីផ្សារ។

**ផ្តល់ភាពងាយស្រួលក្នុងការទូទាត់ប្រាក់៖** ការទូទាត់ដោយមិនប្រើក្រដាសប្រាក់ (Cashless Payment) ក៏បានជួយឱ្យការទិញទំនិញរបស់អតិថិជនមានភាពងាយស្រួល លឿន និងមានសុវត្ថិភាពជាងមុន។ ដោយសារគុណប្រយោជន៍ទាំងនេះ សហគ្រាសធុនតូច និងមធ្យមអាចទាក់ទាញអតិថិជនបានច្រើនជាងមុន។ ការទូទាត់ដោយមិនប្រើក្រដាសប្រាក់ ក៏អាចជួយឱ្យសហគ្រាសធ្វើការគ្រប់គ្រងប្រាក់ខែបុគ្គលិក និងការរាប់សាច់ប្រាក់បានយ៉ាងលឿន និងចំណេញពេលវេលា។

**កាត់បន្ថយការចំណាយ៖** បច្ចេកវិទ្យាមិនត្រឹមតែជួយកាត់បន្ថយការចំណាយលើប្រតិបត្តិការការងារ និងការគ្រប់គ្រងប្រាក់ប៉ុណ្ណោះទេ តែបច្ចេកវិទ្យាមួយចំនួន ដូចជា ប្រព័ន្ធកុំព្យូទ័រក្លោដក៏បានជួយ

កាត់បន្ថយការចំណាយរបស់ក្រុមហ៊ុន ដោយអនុញ្ញាតឱ្យសហគ្រាស ធ្វើការចែករំលែកទិន្នន័យជាមួយកុំព្យូទ័រ និងឧបករណ៍ផ្សេងទៀតតាមតម្រូវការ។

➤ **ពង្រឹងសន្តិសុខ៖** អាជីវកម្មមួយចំនួនកំពុងប្រឈមនឹងការគំរាមកំហែងផ្នែកសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត។ បច្ចេកវិទ្យាថ្មីៗបានផ្តល់លទ្ធភាពដល់សហគ្រាសធុនតូច និងមធ្យមក្នុងការការពារធនធាន រួមមាន ទិន្នន័យហិរញ្ញវត្ថុ និងព័ត៌មានសម្ងាត់ដែលធ្វើឱ្យក្រុមហ៊ុនអាចរក្សាភាពប្រកួតប្រជែង។ បច្ចេកវិទ្យាបានជួយឱ្យអាជីវកម្មការពារទិន្នន័យសំខាន់របស់ពួកគេពីការលេចធ្លាយទៅកាន់ដៃគូប្រកួតអាជីវកម្ម ដែលបច្ចេកវិទ្យាទាំងនោះអាចមានដូចជាពាក្យសម្ងាត់កុំព្យូទ័រ និងកូដនីយកម្ម (Encryption)។

➤ **កសាងទំនុកចិត្ត៖** ការកសាងទំនុកចិត្តពីអតិថិជនអាចជួយឱ្យសហគ្រាសធុនតូច និងមធ្យមមានភាពប្រកួតប្រជែងខ្ពស់។ បច្ចេកវិទ្យាថ្មីៗមិនត្រឹមតែអាចជួយការពារទិន្នន័យសំខាន់ៗរបស់ក្រុមហ៊ុនប៉ុណ្ណោះទេ តែក៏អាចជួយការពារទិន្នន័យរបស់អតិថិជន។ ការការពារឯកជនភាពជាមូលដ្ឋានគ្រឹះនៃការបង្កើតកេរ្តិ៍ឈ្មោះល្អសម្រាប់សហគ្រាសធុនតូច និងមធ្យម ដែលជាផ្នែកមួយជួយឱ្យអាជីវកម្មរបស់ពួកគាត់មានប្រៀបជាងដៃគូប្រកួត។

## III. ឥទ្ធិពលនៃវិបត្តិជំងឺកូវីដ-១៩ លើការប្រើប្រាស់បច្ចេកវិទ្យារបស់សហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា

ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ បានបង្កផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរចំពោះសកម្មភាពសេដ្ឋកិច្ចសង្គមស្ទើរគ្រប់វិស័យនៅកម្ពុជា ជាពិសេសវិស័យដែលរងគ្រោះខ្លាំងជាងគេគឺ វិស័យទេសចរណ៍ វិស័យផលិតកម្មសម្រាប់ការនាំចេញ និងវិស័យសំណង់។ បើយោងតាមការស្ទង់មតិពី ១ ០០០សហគ្រាសធុនតូច និងមធ្យមក្នុងវិស័យទេសចរណ៍ដោយមូលនិធិអាស៊ីកាលពីខែសីហា ឆ្នាំ២០២១នេះ បានបង្ហាញថា ៧៨% នៃអាជីវកម្មបានរងផលប៉ះពាល់ ដោយសារការថយចុះយ៉ាងខ្លាំងនៃចំនួនភ្ញៀវទេសចរអន្តរជាតិ។ ម៉្យាងទៀត វិបត្តិជំងឺកូវីដ-១៩ ក៏បានធ្វើឱ្យមានការផ្លាស់ប្តូរឥរិយាបថរបស់អតិថិជនក្នុងការទិញទំនិញ ដោយអតិថិជនភាគច្រើនបានសម្របខ្លួននឹងការទិញទំនិញតាមប្រព័ន្ធអនឡាញ។ ការធ្លាក់ចុះប្រាក់ចំណូល និងតម្រូវការកើនឡើងនៃការទិញទំនិញតាមអនឡាញ បានតម្រូវឱ្យសហគ្រាសត្រូវសម្របខ្លួនក្នុងការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។ យោងតាមគេហទំព័រភ្នំពេញប៉ុស្តិ៍ សហគ្រាសធុនតូច និងមធ្យមនៅតាមបណ្តាប្រទេសក្នុងតំបន់អាស៊ាន រួមទាំងប្រទេសកម្ពុជា បានចាត់ទុកការវិនិយោគលើបច្ចេកវិទ្យាជាអាទិភាពចម្បង ហើយវិបត្តិជំងឺកូវីដ-១៩ បានជំរុញការផ្លាស់ប្តូរកាន់តែរហ័សឆ្ពោះទៅរកឌីជីថលូបនីយកម្ម និងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។ នៅក្នុងពេលវិបត្តិជំងឺកូវីដ-១៩ សហគ្រាសដែលសម្របខ្លួនបានល្អទៅនឹងការប្រើប្រាស់បច្ចេកវិទ្យាអាចរក្សាភាពប្រកួតប្រជែងខ្ពស់ ខណៈដែលសហគ្រាសមួយចំនួនទៀតបានជួបប្រទះការលំបាកក្នុងការធ្វើអាជីវកម្ម។ សហគ្រាសធុនតូច និងមធ្យមដែលផ្តល់សេវាដឹកជញ្ជូនអាហារ និងសម្ភារៈផ្សេងៗ ដោយប្រើប្រាស់កម្មវិធីទូរស័ព្ទកំពុងមានសក្តានុពលយ៉ាងខ្លាំង ដោយសារបច្ចេកវិទ្យានេះអាចបំពេញតម្រូវការអតិថិជនអំឡុងពេលនៃការរីករាលដាលនៃជំងឺកូវីដ-១៩។ ជាឧទាហរណ៍ ការលក់របស់ Grocerdel ដែលជាសហគ្រាសធុនតូច

ផ្គត់ផ្គង់នូវកសិផលស្រស់ និងផលិតផលផលិតក្នុងស្រុកនៅក្នុងរាជធានីភ្នំពេញ បានកើនឡើង ១៦៥% ដោយសារអតិថិជនងាកមកទិញទំនិញអនឡាញ ហើយបានជំរុញឱ្យបង្កើនចំនួនបុគ្គលិក ៥០% បន្ថែមទៀត។

## IV. កត្តាជំរុញឱ្យសហគ្រាសធុនតូច និងមធ្យមនៅកម្ពុជាទទួលបានអត្ថប្រយោជន៍ពេញលេញពីការប្រើប្រាស់បច្ចេកវិទ្យា

ខាងក្រោមនេះជាកត្តាសំខាន់ៗដែលជំរុញឱ្យសហគ្រាសធុនតូច និងមធ្យមទទួលបានផលប្រយោជន៍ពេញលេញពីការប្រើប្រាស់បច្ចេកវិទ្យា ពិសេសអំឡុងពេលវិបត្តិជំងឺកូវីដ-១៩៖

**១. បណ្តុះបណ្តាលបុគ្គលិកលើជំនាញឌីជីថល៖** យោងតាមការស្ទង់មតិនៅក្នុងឆ្នាំ២០២១នេះ របស់ DataU, USAID និង the American Chamber of Commerce លើក្រុមហ៊ុនប្រមាណ ២០០ ដែលមានបុគ្គលិកតិចជាង ៥០ នាក់រហូតដល់ក្រុមហ៊ុនដែលមានបុគ្គលិកលើសពី ១ ០០០ នាក់ បានបង្ហាញថាមានតែក្រុមហ៊ុន ១ (មួយ) ក្នុងចំណោម ៥ (ប្រាំ) ក្រុមហ៊ុនប៉ុណ្ណោះ ដែលគិតថាបុគ្គលិករបស់ពួកគេក្នុងពេលបច្ចុប្បន្នមានជំនាញគ្រប់គ្រាន់ដែលសមស្របសម្រាប់បរិវត្តកម្មឌីជីថលក្នុងរយៈពេល៥ឆ្នាំទៅមុខទៀត។ ដូច្នេះ សហគ្រាសធុនតូច និងមធ្យមមានភាពចាំបាច់ក្នុងការផ្តល់នូវការបណ្តុះបណ្តាលជំនាញទាក់ទងនឹងការប្រើប្រាស់បច្ចេកវិទ្យាដល់បុគ្គលិករបស់ខ្លួន។ ជំនាញឌីជីថលដែលមានប្រយោជន៍សម្រាប់បុគ្គលិក រួមមាន ការប្រើប្រាស់សារអេឡិចត្រូនិក, ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម, ការទូទាត់តាមប្រព័ន្ធអ៊ីនធឺណិត, ការប្រើប្រាស់ឧបករណ៍ឆ្លាត, ការការពារឯកជនភាព, ការធ្វើទីផ្សារឌីជីថល, ការគ្រប់គ្រងទិន្នន័យ, ការវិភាគ និងបកស្រាយទិន្នន័យ, និងការរចនាក្រាហ្វិក ជាដើម។ ការបណ្តុះបណ្តាលនេះអាចឱ្យនិយោជិតរៀបចំខ្លួនក្នុងការទទួលយកនូវការផ្លាស់ប្តូរ និងសម្របខ្លួនជាមួយនឹងបច្ចេកវិទ្យា ដែលនឹងជួយបង្កើនផលិតភាពរបស់បុគ្គលិក សំដៅបង្កើនប្រសិទ្ធភាពការងាររបស់សហគ្រាស។

**២. បង្កើតគេហទំព័រ ឬកម្មវិធីទូរស័ព្ទ៖** យោងតាមក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ប្រទេសកម្ពុជាមានអ្នកប្រើប្រាស់អ៊ីនធឺណិតតាមទូរស័ព្ទចល័តចំនួន ១៦.៧ លាននាក់ និងមានការតភ្ជាប់អ៊ីនធឺណិតល្បឿនលឿនចំនួន ២១៥ ០០០ នៅឆ្នាំ២០២០។ ម៉្យាងទៀត ដោយសារវិបត្តិជំងឺកូវីដ-១៩ ប្រជាជនមានការប្រុងប្រយ័ត្នខ្ពស់ដែលធ្វើឱ្យពួកគាត់ផ្លាស់ប្តូរឥរិយាបថក្នុងការទិញទំនិញដោយជ្រើសយកការទិញទំនិញតាមប្រព័ន្ធអនឡាញដើម្បីកាត់បន្ថយហានិភ័យនៃការឆ្លងជំងឺនេះ។ ហេតុនេះហើយសហគ្រាសធុនតូច និងមធ្យមនៅកម្ពុជាគួរបង្កើតជាគេហទំព័រ ឬកម្មវិធីទូរស័ព្ទ ដើម្បីអនុញ្ញាតឱ្យពួកគេអាចលក់ផលិតផល ឬសេវាកម្មទៅដល់អតិថិជនគោលដៅបានច្រើនជាងមុន ដោយអតិថិជនអាចស្វែងរកផលិតផល ឬទំនិញបានលឿន និងងាយស្រួលជាងមុន។

**៣. ប្រើប្រាស់បណ្តាញសង្គម៖** យោងតាមទិន្នន័យរបស់ Statista គិតត្រឹមឆ្នាំ២០២១នេះ បានបង្ហាញថា ៧១.៣% នៃចំនួនប្រជាជនកម្ពុជាគឺជាអ្នកប្រើប្រាស់សកម្មនៅលើបណ្តាញសង្គម។ ដូច្នេះ សហគ្រាស

ធុនតូច និងមធ្យមនៅកម្ពុជាគួរប្រើប្រាស់បណ្តាញសង្គមដើម្បីផ្សព្វផ្សាយផលិតផល ឬសេវាកម្ម និងពង្រឹងទំនាក់ទំនងជាមួយអតិថិជនគោលដៅនៅអំឡុងពេលវិបត្តិជំងឺកូវីដ-១៩។ ដើម្បីបង្កើនប្រសិទ្ធភាពការធ្វើទីផ្សារតាមអនឡាញ សហគ្រាសនៅកម្ពុជាអាចប្រើប្រាស់តិចនិកមួយចំនួនដូចជា ចៀសវាងការផ្សព្វផ្សាយមាតិកាដូចគ្នាច្រើនដង, ផ្តោតលើការស្រាវជ្រាវបន្ថែមសម្រាប់គាំទ្រដល់សកម្មភាពផ្សព្វផ្សាយ និងបង្កើនប្រសិទ្ធភាពការផ្សាយពាណិជ្ជកម្មរបស់បញ្ជីផលិតផល តាមរយៈការភ្ជាប់រូបភាពជាមួយនឹងការពិពណ៌នាផលិតផលនៅលើ Search Result Pages ដើម្បីទទួលបានការគាំទ្រកាន់តែច្រើនពីអតិថិជន។

***៤. សម្រួលដំណើរការគណនេយ្យ៖*** ចំពោះសហគ្រាសធុនតូច និងមធ្យមនៅកម្ពុជាដែលមិនមានលទ្ធភាពក្នុងការជួលគណនេយ្យករពេញម៉ោង ក៏អាចទាញយកផលប្រយោជន៍ពីបច្ចេកវិទ្យាបានដោយប្រើប្រាស់កម្មវិធីមួយចំនួន ដូចជា QuickBooks, Xero, FreshBooks, Wave និងSage 50។ បច្ចេកវិទ្យាទាំងនេះមានសមត្ថភាពក្នុងការដោះស្រាយការងារមួយចំនួន ដូចជា ការចេញវិក័យបត្រដោយស្វ័យប្រវត្តិនៅពេលមានការបញ្ជាទិញ, ការតាមដានការចំណាយ, ការគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌ, ការគណនាពន្ធ និងការបង្កើតរបាយការណ៍ហិរញ្ញវត្ថុ ។

***៥. វិនិយោគលើកម្មវិធីបម្រុងទុក (Backup Software)៖*** ទោះបីជាបច្ចេកវិទ្យាអនុញ្ញាតឱ្យមានការធ្វើការពីចម្ងាយបានក៏ដោយ តែដើម្បីទទួលបានអត្ថប្រយោជន៍ពេញលេញពីបច្ចេកវិទ្យាទាំងនេះ សហគ្រាសធុនតូច និងមធ្យមនៅកម្ពុជាក៏គួរគិតគូរពីការវិនិយោគលើប្រព័ន្ធបម្រុងទុក (Backup System) ដើម្បីជៀសវាងការបាត់បង់ឯកសារ។ លើសពីនេះទៀត សហគ្រាស ក៏អាចប្រើប្រាស់ការផ្ទុកទិន្នន័យនៅលើក្លោដ ដូចជា DropBox, iCloud, Google Drive, Microsoft One Drive, IDrive, Mega, Box, pCloud, Tresorit និង Amazon Drive ដែលអាចធានាបាននូវសុវត្ថិភាពចំពោះឯកសារសំខាន់ៗនានារបស់ក្រុមហ៊ុន។

***៦. ប្រើប្រាស់បច្ចេកវិទ្យាដើម្បីពង្រឹងទំនាក់ទំនងជាមួយអតិថិជន៖*** សហគ្រាសធុនតូច និងមធ្យមគួរចាប់យកឱកាសក្នុងការពង្រឹងទំនាក់ទំនងជាមួយអតិថិជនដើម្បីពង្រីកវិសាលភាពអាជីវកម្មរបស់ខ្លួន។ ពួកគេអាចទាញយកផលប្រយោជន៍ពីបច្ចេកវិទ្យាដោយប្រើប្រាស់នូវប្រព័ន្ធគ្រប់គ្រងទំនាក់ទំនងអតិថិជន (Customer Relationship Management) មួយចំនួន ដូចជា Oracle CRM, Salesforce, Microsoft Dynamics, Insightly និង Capsule CRM។ ជាមួយនឹងបច្ចេកវិទ្យាទាំងនេះ សហគ្រាសអាចរក្សាទិន្នន័យរបស់អតិថិជននៅក្នុងឃ្លាំងសុវត្ថិភាព ហើយទិន្នន័យទាំងនោះអាចឱ្យសហគ្រាសយល់ច្បាស់ពីតម្រូវការរបស់អតិថិជន ដែលអាចជួយដល់ការរក្សាអតិថិជនចាស់ និងទាក់ទាញអតិថិជនថ្មីៗ។

***៧. បង្កើនការចូលរួមរបស់អតិថិជន (Customer Engagement)៖*** យោងតាមគេហទំព័រ The Economic Times ការបង្កើនការចូលរួមរបស់អតិថិជនអាចបង្កើនការលក់ ៦០% បន្ថែមទៀតទៅឱ្យអតិថិជន

ដែលមានស្រាប់។ ហេតុនេះហើយ សហគ្រាសធុនតូច និងមធ្យមនៅកម្ពុជាគួរបង្កើនការចូលរួមរបស់អតិថិជន តាមរយៈការបើកឱ្យអតិថិជនបញ្ចេញមតិយោបល់នៅលើបណ្តាញសង្គម គេហទំព័រ ឬកម្មវិធីទូរស័ព្ទដើម្បីអាចដឹងពីកម្រិតនៃការពេញចិត្តរបស់អតិថិជន ដែលជាទិន្នន័យសំខាន់សម្រាប់កែលម្អផលិតផល ឬសេវាកម្មរបស់ខ្លួន។ លើសពីនេះទៅទៀត សហគ្រាសក៏អាចធ្វើការការវិភាគប្រព័ន្ធផ្សព្វផ្សាយសង្គម(Social Media Analysis) ដើម្បីស្វែងយល់ពីអតិថិជនឱ្យកាន់តែច្បាស់, ដឹងពីដៃគូប្រកួត, ដឹងពីបណ្តាញសង្គមណាមួយដែលត្រូវនឹងអាជីវកម្មបំផុត, បង្កើតមាតិកា និងយុទ្ធសាស្ត្រដែលល្អប្រសើរជាងមុន និងយល់ដឹងកាន់តែស៊ីជម្រៅពីដំណើរការប្រព័ន្ធផ្សព្វផ្សាយសង្គមរបស់ពួកគេ។

## V. កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការលើកស្ទួយការប្រើប្រាស់បច្ចេកវិទ្យាក្នុងវិស័យសហគ្រាសធុនតូច និងមធ្យម

ជានិច្ចកាល រាជរដ្ឋាភិបាលតែងយកចិត្តទុកដាក់ និងផ្តល់ការគាំទ្រដល់ការរីកលូតលាស់នៃសហគ្រាសធុនតូច និងមធ្យម ដែលជាផ្នែកមួយដ៏សំខាន់នៃវិស័យឯកជន ជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ចជាតិ។ ខាងក្រោមនេះជាកិច្ចខិតខំប្រឹងប្រែងមួយចំនួនរបស់រាជរដ្ឋាភិបាលក្នុងការគ្រាំទ្រ និងលើកស្ទួយការប្រើប្រាស់បច្ចេកវិទ្យានៅក្នុងវិស័យសហគ្រាសធុនតូច និងមធ្យម៖

**ទី១.** រាជរដ្ឋាភិបាលបានពង្រឹងការយល់ដឹងពីបច្ចេកវិទ្យាដល់សហគ្រាសធុនតូច និងមធ្យម តាំងពីមុនពេលមានការផ្ទុះឡើងនៃវិបត្តិជំងឺកូវីដ-១៩។ តួយ៉ាង ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍បានរៀបចំសិក្ខាសាលាដែលមានឈ្មោះថា "Tech-Startups and MSMEs Go Digital" ដើម្បីផ្សព្វផ្សាយនិងបញ្ជ្រាបការយល់ដឹងពីការចាប់យកបច្ចេកវិទ្យាថ្មីៗ ដែលមានសារៈសំខាន់សម្រាប់អាជីវកម្ម។

**ទី២.** ថ្មីៗនេះ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍បានសហការជាមួយទីភ្នាក់ងារអូស្ត្រាលីសម្រាប់ការអភិវឌ្ឍអន្តរជាតិ(AUSAID) និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិប្រចាំនៅប្រទេសកម្ពុជា (UNDP) ក្នុងគោលបំណងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចក្រោយវិបត្តិកូវីដ-១៩ ក្នុងនោះបានផ្តោតសំខាន់លើការលើកកម្ពស់ការយល់ដឹងពីអត្ថប្រយោជន៍ និងពង្រឹងសមត្ថភាពរបស់សហគ្រាសធុនតូច និងមធ្យមក្នុងការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

**ទី៣. ក្រសួងទេសចរណ៍ សហភាពសហព័ន្ធយុវជនកម្ពុជា** សហការជាមួយ**មជ្ឈមណ្ឌលកម្ពុជា ៤.០** បានរៀបចំ "**វគ្គបណ្តុះបណ្តាលអក្ខរកម្មឌីជីថលក្នុងវិស័យទេសចរណ៍កម្ពុជា**" រួមមានអក្ខរកម្មមូលដ្ឋាន និងអក្ខរកម្មជំនាញ ដើម្បីចូលរួមអភិវឌ្ឍន៍ចំណេះ និងជំនាញឌីជីថលសម្រាប់បុគ្គលិកឯកជនបម្រើការងារក្នុងវិស័យទេសចរណ៍ ម្ចាស់អាជីវកម្ម ឬបុគ្គលដែលមានបំណងចង់បង្កើតធុរកិច្ចថ្មី(Startups) នៅក្នុងវិស័យទេសចរណ៍។ វគ្គបណ្តុះបណ្តាលនេះផ្តោតលើប្រធានបទដែលមានសារៈសំខាន់សម្រាប់ការបំពេញការងារ និងការប្រកបអាជីវកម្មក្នុងវិស័យទេសចរណ៍ រួមមាន ការប្រើប្រាស់សារអេឡិចត្រូនិក, ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម, ការទូទាត់តាមប្រព័ន្ធអ៊ីនធឺណិត, ការប្រើប្រាស់ឧបករណ៍ឆ្លាត, ការការពារឯកជនភាព, ការធ្វើទីផ្សារឌីជីថល, ការគ្រប់គ្រងទិន្នន័យ, ការវិភាគ និងបកស្រាយទិន្នន័យ,

ការរចនាក្រាហ្វិក និងសហគ្រិនឌីជីថលជាដើម សំដៅបង្កើនផលិតភាព ប្រសិទ្ធភាពការងារ និងអាជីវកម្ម។

**ទី៤.** ក្រសួងពាណិជ្ជកម្ម សហការជាមួយកម្មវិធីពង្រឹងក្របខ័ណ្ឌសមាហរណកម្ម (EIF) និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិប្រចាំនៅប្រទេសកម្ពុជា (UNDP) បានដាក់ឱ្យដំណើរការគម្រោង "Go4eCam" ដែលបង្កើតឡើងក្នុងគោលបំណងជំរុញការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិករបស់សហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា។ គម្រោងនេះនឹងផ្តល់ឱកាសឱ្យសហគ្រាសធុនតូច និងមធ្យមក្នុងស្រុកចាប់យកទីផ្សារឌីជីថល ដើម្បីអាចផ្សព្វផ្សាយដល់អតិថិជនគោលដៅបានកាន់តែច្រើនជាមួយបច្ចេកវិទ្យា។ នៅក្នុងក្របខ័ណ្ឌនៃគម្រោងនេះ ក្រសួងពាណិជ្ជកម្មបានបង្កើតគេហទំព័រ Cambodiatrade.com ដែលជាថ្នាល ផ្សារពាណិជ្ជកម្មអេឡិចត្រូនិកដំបូងគេនៅកម្ពុជា កាលពីខែមិថុនា ឆ្នាំ២០២១ ដើម្បីបង្កើនឱកាសសេដ្ឋកិច្ចសម្រាប់សហគ្រាសធុនតូច និងមធ្យមក្នុងស្រុក។

**ទី៥.** ជាមួយគ្នានេះ រាជរដ្ឋាភិបាលបានបង្កើត "មូលនិធិអភិវឌ្ឍន៍ជំនាញ" (Skill Development Fund), "មូលនិធិអភិវឌ្ឍន៍សហគ្រិនភាព" (Entrepreneurship Development Fund) និងធនាគារសហគ្រាសខ្នាតតូច និងមធ្យមកម្ពុជា (SME Bank of Cambodia) ក្នុងគោលបំណងពង្រឹងជំនាញ និងការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុដល់សហគ្រាសធុនតូច និងមធ្យម ក៏ដូចជាធុរកិច្ចថ្មី ក្នុងការចាប់យក និងប្រើប្រាស់បច្ចេកវិទ្យាឌីជីថល។

## VI. សន្និដ្ឋាន

ជារួម សហគ្រាសធុនតូច និងមធ្យម បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងចរន្តសេដ្ឋកិច្ចជាតិ ដោយជាផ្នែកមួយចូលរួមពង្រឹងខ្សែច្រវាក់ផលិតកម្មនៅក្នុងវិស័យឯកជនដែលជាក្បាលម៉ាស៊ីននៃកំណើន។ ជាមួយការមកដល់នៃបដិវត្តន៍ឧស្សាហកម្ម ៤.០ ក៏ដូចជាការប្រែប្រួលនៃតម្រូវការ និងការផ្គត់ផ្គង់ដោយសារឥទ្ធិពលនៃវិបត្តិជំងឺកូវីដ-១៩ សហគ្រាសធុនតូច និងមធ្យម មានភាពចាំបាច់ក្នុងការចាប់យក និងសម្របខ្លួនជាមួយការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ ដើម្បីរក្សាបាននូវភាពប្រកួតប្រជែង និងនិរន្តរភាពនៃអាជីវកម្ម៕

## ឯកសារយោង៖


- *Small and Medium Enterprises (SMEs) Finance, ចូលអានថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១*, https://www.worldbank.org/en/topic/smefinance
- *ទស្សនទានស្តីពីមីក្រូសហគ្រាស សហគ្រាសធុនតូច និងមធ្យមនៅប្រទេសកម្ពុជា, ចូលអានថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១*, http://rac.gov.kh/royal-academy/research/attachments/original/21.pdf?1546423309
- *រដ្ឋាភិបាលកំណត់លក្ខខណ្ឌថ្មីសម្រាប់និយមន័យសហគ្រាសធុនតូច និងមធ្យមថ្មី, ចូលអានថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១*, https://www.khmertimeskh.com/50806874/%E1%9E%9A%E1%9E%8A%E1%9E%8B%E1%9E%97%E1%9E%94%E1%9E%9B%E1%9E%80%E1%9E%8E%E1%9E%8F%E1%9E%9B%E1%9E%80%E1%9E%81%E1%9E%81%E1%9E%8E/
- *Understanding Cambodian Small and Medium Enterprise Needs for Financial Services and Products, ចូលអានថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១*, https://documents1.worldbank.org/curated/en/377261468014381044/pdf/603690NWP0KH0S10BOX358315B01PUBLIC1.pdf
- *Report Reveals COVID-19's Deep Impact on Cambodian Tourism Economy, ចូលអានថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១*, https://thediplomat.com/2021/08/report-reveals-covid-19s-deep-impact-on-cambodian-tourism-economy/
- *To thrive in e-commerce, SMEs need the right skills and gov't help, ចូលអានថ្ងៃទី១៨ ខែតុលាឆ្នាំ២០២១*, https://www.phnompenhpost.com/opinion/thrive-e-commerce-smes-need-right-skills-and-govt-help
- *Cambodia's digital startups help blunt economic impact of COVID-19, ចូលអានថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១*, https://unctad.org/es/node/3045
- *Telcos and Mobile Devices in Cambodia, ចូលអានថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១*, https://www.b2b-cambodia.com/articles/telcos-and-mobile-devices-in-cambodia/
- *Lack of staff to cope with vital move to Industry 4.0, ចូលអានថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១*, https://www.khmertimeskh.com/50951405/lack-of-staff-to-cope-with-vital-move-to-industry-4-0/
- *Digitally adapting to economic challenges, ចូលអានថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២១*,https://www.khmertimeskh.com/50784394/digitally-adapting-to-economic-challenges/
- *10 Ways to Take Advantage of Technology in Your Business, ចូលអានថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១*, https://clutch.co/agencies/resources/ways-take-advantage-technology-business
- *A CRM Is Not Just a Customer Relationship Management System, ចូលអានថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១*, https://www.softwaresuggest.com/blog/customer-relationship-management-system/
- *New digital push for MSMEs, ចូលអានថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១*,https://www.phnompenhpost

.com/business/new-digital-push-msmes

- *Digitalisation in Cambodian SMEs: Q&A with Kan Channmeta*, ចូលអានថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១, https://www.khmertimeskh.com/496642/digitalisation-in-cambodian-smes-qa-with-kan-channmeta/
- *Pilot project to boost e-commerce for Kingdom's SMEs*, ចូលអានថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១, https://www.khmertimeskh.com/686950/pilot-project-to-boost-e-commerce-for-kingdoms-smes/
- *Wing Bank signs on to ministry's CambodiaTrade*, ចូលអានថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១, https://www.phnompenhpost.com/business/wing-bank-signs-ministrys-cambodiatrade
- *Cambodia Digital Economy and Society Policy Framework 2021 – 2035*, ចូលអានថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១, https://mef.gov.kh/download-counter?post=7116
- *Benefits Of ICT in Smes Information Technology Essay*, ចូលអានថ្ងៃទី២២ ខែតុលា ឆ្នាំ២០២១, https://www.ukessays.com/essays/information-technology/benefits-of-ict-in-smes-information-technology-essay.php
- *How eCommerce Helps the Growth of SMEs*, ចូលអានថ្ងៃទី២២ ខែតុលា ឆ្នាំ២០២១, https://www.ebeyonds.com/blog/ecommerce-for-smes.html
- គេហទំព័រនៃក្រសួងពាណិជ្ជកម្ម, ចូលអានថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២១, https://www.moc.gov.kh/

---

www.cambodia4point0.org

កម្ពុជា ៤.០ - Cambodia 4.0

cambodia_4.0

កម្ពុជា ៤.០ Cambodia 4.0

កម្ពុជា ៤.០ - Cambodia 4.0

កម្ពុជា ៤.០ - Cambodia 4.0

Cambodia 4.0 Center

Cambodia 4.0